**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
**ក្រឡាការព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៥៦២ អ.ក
ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២
សំណុំរឿងស៊ើបសួរលេខ ១៦១ ស.ស
ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ ១៤៧៥ ជ.វ
ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌលេខ ០០៥ ឋ
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

កាលបរិច្ឆេទនៃសវនាការ ៖ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣។
សាលសវនាការ និងពេលវេលា ៖ សាល ០១ ម៉ោង ០២ រសៀល។
កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣។
សាលសវនាការ និងពេលវេលា ៖ សាល ០១ ម៉ោង ០៣ នាទីរសៀល។
ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

ឈ្មោះ [redacted] **ទិត្យ** ភេទប្រុស កើតឆ្នាំ១៩៨៥ (អាយុ ៣៥ ឆ្នាំ) ជនជាតិខ្មែរ មុខរបរ កសិករ។

ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្ដាល។

ទីលំនៅភូមិ[redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] វុន (ស) ម្ដាយឈ្មោះ [redacted] ណែម (ស) ប្រពន្ធឈ្មោះ [redacted] សុនាថ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។ (ក្រៅឃុំ)

ត្រូវជាប់ចោទពីបទ **ប្រើប្រាស់ឯកសារក្លែង** ប្រព្រឹត្តនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យផ្ទះលេខ៥៧-៥៩ ផ្លូវបេតុង ភូមិទ្រា៤ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។



Scanned with CamScanner

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

លោកស្រី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យអាគារមិលលីនញ៉ូមលេខ៦៨ (ជាន់ទី៣) ផ្លូវលេខ ៥៧ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យស្ថិតនៅសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ជាន់ទី១០ អាគារលេខ៣៦ ផ្លូវ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យផ្ទះលេខ ៣៥ ផ្លូវ NW-១០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**សំណុំរឿងព្រហ្មទណ្ឌនេះត្រូវបានបញ្ជូនមកជំនុំជម្រះតាម ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៥១៥ ដកដស ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ដែលមាន៖**

**អង្គហេតុដែលប្ដឹងមកតុលាការមានដូចតទៅ**

កាលពីអំឡុងឆ្នាំ២០២០ ឈ្មោះ [redacted] ទិត្យ បានលួចក្លែងស្នាមមេដៃរបស់ឈ្មោះ [redacted] មេ ឈ្មោះ [redacted] ជ្រឹម លើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១២២០ បជ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩២ និងកំណត់ហេតុអង្កេតដីដែលមានស្នាមមេដៃរបស់ឈ្មោះ [redacted] មេ ទទួលស្គាល់ជាអ្នកជាប់ព្រំខាងត្បូង និងលិខិតកាន់កាប់ដីធ្លីលេខ ១២៩០ បជ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ និងកំណត់ហេតុអង្កេតដីដែលមានស្នាមមេដៃរបស់ឈ្មោះ [redacted] ជ្រឹម ទទួលស្គាល់ជាអ្នកជាប់ព្រំខាងកើត ដែលមានទីតាំងស្ថិតនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល បន្ទាប់មកឈ្មោះ [redacted] ទិត្យ បានយកលិខិតក្លែងទាំងពីរខាងលើទៅប្រើប្រាស់ជាសាធារណៈ។

**អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្ដី**

**ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្ដី**

អំពីវិវាទកម្មស្ដីពីនិយតភាពនៃការកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន។

**ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្ដី**

**១. ការសួរចម្លើយជនជាប់ចោទ**

**១.១.** ជនជាប់ចោទឈ្មោះ [redacted] **ទិត្យ៖** ខ្លួនស្គាល់ឈ្មោះ [redacted] មេ ត្រូវជាបងប្អូន (ត្រូវជាអ៊ុំ) ខាងម្ដាយរបស់ខ្លួន។ ខ្លួនរស់នៅក្នុងភូមិកណ្ដាលលើ តាំងពីកើត។ ចំពោះលិខិតលេខ ១២២០ បជ លិខិតលេខ ១២៩០ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ ខ្លួនសូមបញ្ជាក់ថា ខ្លួនសូមថតចម្លងពីសុរិយោដីស្រុកនៅឆ្នាំ២០២១ ក្រោយពីថតចម្លងលិខិតនេះរួច ខ្លួនក៏បានដាក់ចូលតុលាការកំពូល ដោយសម្រេចកាត់ដីដែលមានលិខិតទាំងពីរនោះមកឱ្យខ្លួន និងអនុវត្តរួចហើយចេញបង្កាន់ដៃហើយទៀត។ ខ្លួនសូមបញ្ជាក់ថា លិខិតនេះមានលេខកូដ កណ្ដាលលើ ឃុំលេខ ១២៩០ កណ្ដាលក្រោមលេខ ១២២០។ កំណត់ហេតុលេខ G២០១៤៣២ គឺខ្លួនមិនចាំកំណត់ហេតុ។ G

៧១២៦២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨៣ គឺខ្លួនមិនចាំនោះទេ។ ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី គឺខ្លួនមានទំនាក់ទំនងធម្មតា ហើយក្រោយមកឃើញដីការកោះខ្លួនក៏ទៅសួរដើមបណ្តឹងរដ្ឋប្បវេណី ថាបានប្តឹងខ្លួនអត់។ ដើមបណ្តឹងរដ្ឋប្បវេណីថា គាត់មិនបានប្តឹងខ្លួននោះទេ។ ឈ្មោះ [redacted] សំឡូត ឈ្មោះ [redacted] សុន និងឈ្មោះ [redacted] សឹម បានសុំស្នាមមេដៃពីគាត់ដោយគាត់ចាស់មិនចេះអក្សរ។ ចំពោះការប្តឹងខ្លួនពីដើមមកខ្លួន និងដើមបណ្តឹងរដ្ឋប្បវេណីមិនធ្លាប់មានទំនាស់ឡើយ។ ចំពោះកំណត់ហេតុអង្កេតដី ដែលតំណាងអយ្យការសួរគឺខ្លួនមិនបានក្លែងស្នាមមេដៃគាត់នោះទេ។ ចំពោះស្នាមមេដៃលើលិខិតផ្ទេរសិទ្ធិ និងកំណត់ហេតុអង្កេតដីគឺខ្លួនមិនបានក្លែងនោះទេ។ ចំពោះការប្តឹងខ្លួនគឺដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរប្រាប់ថា គាត់មិនបានប្តឹងខ្លួននោះទេ។ ចំពោះដីនោះគឺជារបស់ឪពុកខ្លួន។ ចំពោះកំណត់ហេតុអង្កេតដី និងលិខិតផ្ទេរសិទ្ធិដីនោះគឺខ្លួនមិនបានដឹងនោះទេ ដោយសារឯកសារនៅឆ្នាំ១៩៩០ជាងឯណោះ។ ចំពោះឯកសារលិខិតផ្ទេរសិទ្ធិគឺចេញពីសុរិយោដីតែម្តង G១៤៣២ គឺខ្លួនមិនបានផ្តិតបន្ថែមទេ នៅកណ្តាលក្រោម G១២៦២ កណ្តាលលើ គឺស្នាមមេដៃគឺមកតែម្តង។ ខ្លួនសូមបញ្ជាក់បន្ថែមថា ឯកសារទាំងពីរខាងលើគឺខ្លួនសុំថតចម្លងពីសុរិយោដី។ ដីនេះជារបស់ឪពុកខ្លួន និងខ្លួន។ ពេលខ្លួនទៅសួរដើមបណ្តឹងទាំងពីរថា "ពូមានបានប្តឹងខ្លួនឡើងតុលាការបទ ក្លែងអត់" ពូ [redacted] ជ្រឹម ថា "ពូគ្មានហេតុផលប្តឹងក្មួយទេ ដោយគាត់ក៏ធ្លាប់ផ្តិតមេដៃឱ្យឈ្មោះ [redacted] គឹម ហើយបុគ្គលនេះធ្លាប់ជួលដីមិននឹកស្មានថា បុគ្គលនេះយកឯកសារអ្វីឱ្យគាត់ផ្តិតទេ។ ក្រោយមកឈ្មោះ [redacted] ជ្រឹម ក៏ដកពាក្យបណ្តឹងឈប់ប្តឹងខ្លួន។ ចំពោះការដកពាក្យបណ្តឹងគឺដើមបណ្តឹងដកដោយសុទ្ធចិត្ត។ មូលហេតុដែលឈ្មោះ [redacted] ជា ឈ្មោះ [redacted] សំឡូត និងឈ្មោះ [redacted] ស៊ឹម ប្រាប់ថា ផ្តិតមេដៃធ្លាប់ជួលដី។ ខ្លួនសូមបញ្ជាក់ថា ឈ្មោះ [redacted] ជា ឈ្មោះ [redacted] សំឡូត និងឈ្មោះ [redacted] ស៊ឹម ធ្លាប់មានវិវាទជាមួយគ្នានៅតុលាការកំពូល។

**២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

**២.១. អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីតំណាងដោយមេធាវី** [redacted]៖ កូនក្តីខ្ញុំបាទពិតជាដាក់ពាក្យបណ្តឹងលើឈ្មោះ [redacted] ទិត្យ ពីបទ ប្រើប្រាស់ឯកសារក្លែងពិតប្រាកដណាស់ ខ្លួនសូមរក្សាចម្លើយនៅក្នុងពាក្យបណ្តឹងរបស់កូនក្តីខ្ញុំបាទឈ្មោះ [redacted] មេ និងឈ្មោះ [redacted] ជ្រឹង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ ទុក ជាបានការដដែល។ កូនក្តីខ្ញុំបាទឈ្មោះ [redacted] មេ ឈ្មោះ [redacted] ជ្រឹង បានអះអាងថា ខ្លួនសុំបដិសេធស្នាមមេដៃរបស់ខ្លួន គឺមិនបានផ្តិតមេដៃលើពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ ១២២០ ដប ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩២ និងលិខិតកាន់កាប់ដីធ្លីលេខ ១២៩០ ដប ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៣។ ប៉ុន្តែស្រាប់តែបានឃើញស្នាមមេដៃរបស់ខ្លួននៅលើលិខិតទាំងពីរខាងលើ ហើយឈ្មោះ [redacted] ទិត្យ បានយកលិខិតដែលមានស្នាមមេដៃរបស់របស់ខ្លួន នៅលើលិខិតខាងលើយកទៅប្រើប្រាស់ជាសាធារណៈ។ សូមជួយរកយុត្តិធម៌ឱ្យកូនក្តីខ្លួនផង ហើយសូមផ្តន្ទាទោសជននេះតាមផ្លូវច្បាប់។

**សិទ្ធិនិយាយស្តីរបស់គាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

**ក. ការកត់សម្គាល់ខ្លីៗរបស់៖**

១. ជនជាប់ចោទឈ្មោះ [redacted] ទិត្យ៖ សំណូមពរតុលាការរកបុគ្គលដែលក្លែងបន្លំ និងរកយុត្តិធម៌ឱ្យខ្លួន។

**ខ. សេចក្តីសន្និដ្ឋាន៖**

**១. សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ៖**

ក្រោយពីបានស្ដាប់ការសាកសួរដេញដោល ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មេ និងឈ្មោះ [redacted] ជ្រឹម មិនបានប្ដឹងខ្លួនទេ តែបើពិនិត្យមើលលិខិតផ្ទេរសិទ្ធិ និងកំណត់ហេតុអង្កេតដី ឃើញថា មានអំពើក្លែងឯកសារប្រាកដមែន ហេតុនេះតំណាងអយ្យការនៅតែ តម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរដដែល។

**២. សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

២.១. លោក [redacted] ធ្វើសេចក្ដីសន្និដ្ឋានថា៖ អង្គហេតុថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ ពាក្យបណ្ដឹងឈ្មោះ [redacted] មេ ឈ្មោះ [redacted] ជ្រឹម ប្ដឹងឈ្មោះ [redacted] ទិត្យ ពីបទ **ប្រើប្រាស់ឯកសារក្លែងលើឯកសារពាក្យសុំ**លេខ ១២៩០ បជ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩២ កំណត់ហេតុឈ្មោះ បែន មេ ទទួលស្គាល់អ្នកជាប់ព្រំប្រទល់ និងពាក្យសុំកាន់កាប់លេខ ១២៩០ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ កំណត់ហេតុអង្កេតដីឈ្មោះ [redacted] ជ្រឹម។ តុលាការបានចោទប្រកាន់បទប្រើប្រាស់លិខិតក្លែង តាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ក្នុងសំណុំរឿងព្រហ្មទណ្ឌចំពោះករណីឈ្មោះ [redacted] មេ ឈ្មោះ [redacted] ជ្រឹម បានដកពាក្យបណ្ដឹងចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជ្រឹម ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] មេ រួចហើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរអះអាងថា គាត់មិនបានប្ដឹងកូនក្ដីខ្ញុំបាទឡើយ។ ស្នាមមេដៃរបស់ពួកគាត់មិនដឹងឡើយ ចំពោះការពឹងពាក់មេធាវី គាត់មិនបានពឹងពាក់ឡើយ។ មាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ បានឱ្យនិយមន័យបទ ប្រើប្រាស់ឯកសារក្លែងថា "***ការប្រើប្រាស់លិខិតក្លែងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល***" ត្រូវពិនិត្យមើលតើលិខិតនេះក្លែង ឬយ៉ាងណា ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានដកពាក្យបណ្ដឹងរួចហើយ។ ការដកពាក្យបណ្ដឹងនាំឱ្យបណ្ដឹងអាជ្ញាត្រូវរលត់ ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានឈប់ប្ដឹងកូនក្ដីខ្ញុំបាទ។ ម្យ៉ាងទៀតតុលាការកំពូលចំណុចទី៤ បានសម្រេចដីដែលមានប័ណ្ណលេខ G៧១២៦២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ G៧១៤៣២ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៣ ផ្អែកតាមគំនូសបង្ហាញទីតាំងទាំង ០២ ទំលាក់ទីតាំងដែលគូសដោយឈ្មោះ មុន្នី អ្នកជំនាញសុរិយោដី ឱ្យទៅសហដើមចោទឈ្មោះ [redacted] លេខា [redacted] លីណា [redacted] លីនី ផង ឈ្មោះ [redacted] ទិត្យ គ្រប់គ្រងកាន់កាប់អាស្រ័យផលលើទីតាំងទាំង ០២។ ហេតុនេះមាត្រា ៣៤២ នៃក្រមព្រហ្មទណ្ឌ សេចក្ដីសម្រេចឱ្យតុលាការកំពូលជាអញ្ញត្តកម្មបញ្ហាបន្ទាន់បង្គំនៃនីតិវិធីព្រហ្មទណ្ឌ អាចទទួលបានលុះត្រាតែករណីដែលបញ្ហាបន្ទាន់បង្គំនេះអាចលុបលាងលើបញ្ហាបន្ទាន់បង្គំចារិកនៃបទល្មើស ដែលសម្រេចចោទប្រកាន់លើជនជាប់ចោទ។ ម្យ៉ាងទៀតករណីនេះតុលាការកំពូលបានផ្ដល់សិទ្ធិឱ្យកូនក្ដីខ្ញុំបាទរួចហើយ។ តាមដីកាលេខ ៦៥ ដស ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ បានលើកចោលពាក្យសុំជំនុំជម្រះសារជាថ្មីរួចហើយ។ កូនក្ដីខ្ញុំបាទមិនបានប្រព្រឹត្តអំពើក្លែងឯកសារឡើយ ហើយការតតាំងឯកសាររបស់អាជ្ញាធរហើយដើមបណ្ដឹងរដ្ឋប្បវេណី មិនបានប្ដឹងកូនក្ដីខ្ញុំបាទឡើយ។ ខ្ញុំបាទស្នើសុំតុលាការទទួលយកបញ្ហាបន្ទាន់បង្គំតាមរយៈសាលដីកាលេខ ៤៩ ង ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់តុលាការកំពូល និងសុំឱ្យកូនក្ដី ខ្ញុំបាទរួចខ្លួនពីបទចោទ។

**៣. សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទជាលាយលក្ខណ៍អក្សរ៖**

**៣.១. អំពីអង្គហេតុ**

កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ មានពាក្យបណ្តឹងប្តឹងមកសាលាដំបូងខេត្តកណ្តាល ដោយឈ្មោះ [redacted] មេ ឈ្មោះ [redacted] ជ្រឹម ដែលបានប្តឹងកូនក្តីខ្ញុំបាទឈ្មោះ [redacted] ទិត្យ ពីបទ ប្រើប្រាស់ឯកសារក្លែង ដែលប្រព្រឹត្តនៅខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២១ លើឯកសារប្រើប្រាស់ដីធ្លីចំនួន ០២ (ពីរ) កន្លែងដូចខាងក្រោម៖

១. ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ១២២០ បង ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩២ និងកំណត់ហេតុអង្កេតដីដែលមានឈ្មោះ [redacted] មេ បានផ្តិតមេដៃទទួលស្គាល់ថា ជាអ្នកជាប់ព្រំខាងត្បូង។

២. ពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ ១២៩០ បង ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ និងកំណត់ហេតុអង្កេតដីដែលមានឈ្មោះ [redacted] ជ្រឹម បានផ្តិតមេដៃទទួលស្គាល់ថា ជាអ្នកជាប់ព្រំខាងកើត។

ចំពោះពាក្យបណ្តឹងខាងលើនេះ ត្រូវបានតុលាការធ្វើការចោទប្រកាន់លើកូនក្តីខ្ញុំឈ្មោះ [redacted] ទិត្យ ពីបទ ***"ប្រើប្រាស់លិខិតក្លែង"*** ផ្អែកតាមមាត្រា ៦២៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៦២ អ.ក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្តាល។ ដើមបណ្តឹងឈ្មោះ [redacted] ជ្រឹម ឈ្មោះ [redacted] មេ ក្នុងសំណុំរឿងនេះបានធ្វើការដកពាក្យបណ្តឹងខាងលើ តាមរយៈលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ជ្រឹម និងលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] មេ រួចហើយ។ ឈ្មោះ [redacted] ជ្រឹម និងឈ្មោះ [redacted] មេ បានបញ្ជាក់ក្នុងលិខិតខាងលើ និងអះអាងចំពោះកូនក្តីខ្ញុំឈ្មោះ [redacted] ទិត្យ ថា ពួកគាត់ពុំបានប្តឹងកូនក្តីខ្ញុំឡើយ ហើយស្នាមមេដៃនៅក្នុងពាក្យបណ្តឹងខាងលើគឺពួកគាត់ទាំងពីរពុំដឹងឡើយ និងមិនដែលធ្វើការពឹងពាក់មេធាវី ឬប្រគល់សិទ្ធិតំណាងឱ្យមេធាវីណាឡើយ ហើយលិខិតដកពាក្យបណ្តឹងនេះ មានការបញ្ជាក់ដឹងឮពីមេភូមិកណ្តាលលើ ឈ្មោះ ក្រូច លីស និង មេឃុំបន្ទាយដែកឈ្មោះ [redacted] សុផាត។ ពួកគាត់ទាំងពីរបានធ្វើការបដិសេធទាំងស្រុងលើពាក្យបណ្តឹងនេះ និងការពឹងពាក់មេធាវី។

### ៣.២. អំពីអង្គច្បាប់

តាមមាត្រា ៦២៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា ***"ការប្រើប្រាស់លិខិត ក្លែងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល"***។ ជាទូទៅ មុននឹងឈានដល់ការកំណត់ បទល្មើសខាងលើ គប្បីពិចារណាថា តើលិខិតដែលយកទៅប្រើប្រាស់ជាឯកសារក្លែង ឬយ៉ាងណា?

**ក. មូលដ្ឋានគតិយុត្ត៖** ដើមចោទឈ្មោះ [redacted] ជ្រឹម ឈ្មោះ [redacted] មេ បានធ្វើការដកពាក្យបណ្តឹងពីដើមបណ្តឹងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៦២ អ.ក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្តាល ដូចមានក្នុងលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ជ្រឹម និងលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] មេ ដែលនេះជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាស្របតាមមាត្រា ៨ កថាខណ្ឌទី ២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា **"ដោយការដកពាក្យប្តឹងនៅក្នុងករណីដែលពាក្យប្តឹងនេះ ជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ"**។ ដោយហេតុថា ដើមបណ្តឹងបានធ្វើការដកពាក្យបណ្តឹងរបស់ខ្លួន ដោយមានការអះអាងថាខ្លួនមិនបានផ្តិតស្នាមមេដៃ



Scanned with CamScanner

និងមិនមានឆន្ទៈក្នុងការប្តឹងកូនក្តីខ្ញុំឈ្មោះ [redacted] ទិត្យ ដូចពាក្យបណ្តឹងឡើយ ម៉្យាងវិញទៀតពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុក និងធ្វើការចោទប្រកាន់លើកូនក្តីខ្ញុំពីបទល្មើសខាងលើឡើយ។

**ខ.មូលដ្ឋាននៃសេចក្តីសម្រេចរបស់តុលាការកំពូល៖** សាលដីការដ្ឋប្បវេណីលេខ ៤៩ "ង" ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់តុលាការកំពូល ត្រង់សេចក្តីសម្រេចបញ្ចប់ ចំណុចទី៤ *"សម្រេចប្រគល់ដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ និងលេខ ៤៧-១៤៣២ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៣ ដោយផ្អែកលើគំនូសបង្ហាញទីតាំងដីទំនាស់ទាំងពីរកន្លែងដែលបានគូសកំណត់អំពីទំហំដី និងទីតាំង ភិនភាគដីនោះ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ ដែលបានគូសដោយមន្ត្រីជំនាញសុរិយោដីនៃមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល ឱ្យទៅសហដើមចោទឈ្មោះ [redacted] លេខា, ឈ្មោះ [redacted] លីណា, ឈ្មោះ [redacted] លីនី និងឈ្មោះ [redacted] ទិត្យ គ្រប់គ្រង កាន់កាប់អាស្រ័យផល ចាត់ចែងក្នុងនាមជាម្ចាស់សិទ្ធិលើដីទាំងពីរកន្លែងនេះតាមច្បាប់"*។ ដែលនេះបង្ហាញឲ្យឃើញពីការសម្រេច ដ៏មានតម្លាភាព សុក្រិត្យ និងយុត្តិធម៌ ជូនកូនក្តីខ្ញុំដែលជាជនរងគ្រោះ។

**គ. ការលុបលាងចរិតនៃបទល្មើសស្របតាមមាត្រា ៣៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា៖** ដោយឡែក សេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់នៃចំណុច ខ ខាងលើជាដំណោះស្រាយនូវបញ្ហាបន្ទាន់បង្គំដែលជាអញ្ញត្រកម្មនៃនីតិវិធីព្រហ្មទណ្ឌ។ ផ្អែកតាមមាត្រា ៣៤៣ ខណ្ឌទី ២ បញ្ហាបន្ទាន់បង្គំ និងការបង្អង់មិនទាន់សម្រេច ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា ***"បញ្ហាបន្ទាន់បង្គំអាចនឹងទទួលបានលុះត្រាតែបញ្ហានេះអាចនឹងលុបលាងចរិតជាបទល្មើសពីអំពើ ដែលចោទប្រកាន់លើជនជាប់ចោទ"***។ បញ្ហាបន្ទាន់បង្គំនេះ គឺជាបញ្ហាដែលអាចនឹងលុបលាងចរិតជាបទល្មើសពីអំពើដែលចោទប្រកាន់ លើបញ្ហាបន្ទាន់បង្គំទាក់ទងនឹង បញ្ហាស្តីពីកម្មសិទ្ធិ សិទ្ធិប្រត្យក្សលើ អចលនវត្ថុ និងរឿងឋានៈបុគ្គល។ ជាក់ស្តែងសេចក្តីសម្រេចអំពីបញ្ហាកម្មសិទ្ធិត្រូវបាន សម្រេចដោយតុលាការជាន់ខ្ពស់រួចហើយ ដូច្នេះបទល្មើសដែលរងការចោទប្រកាន់ គឺពុំអាចទៅរួចឡើយ។

**ឃ. ការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិ៖** ក្នុងករណីវិវាទដីនេះ កន្លងមកឈ្មោះ [redacted] ផុន ឈ្មោះ [redacted] ស៊ីអេង បានធ្វើការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មីចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ទៅតុលាការកំពូល ហើយត្រូវបានតុលាការកំពូលធ្វើការច្រានចោលកាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ តាមដីកាសម្រេចលេខ ៦៥ ដ.ស (ង) ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ដែលនេះបញ្ជាក់ពីការ អស់សិទ្ធិក្នុងការបន្តនីតិវិធីបណ្តឹងតាមប្រព័ន្ធតុលាការលើករណីវិវាទដីទាំង ០២ (ពីរ) កន្លែងនេះ។

**៣.៣. សេចក្តីសន្និដ្ឋាន**

កូនក្តីខ្ញុំឈ្មោះ [redacted] ទិត្យ មិនបានប្រើប្រាស់ឯកសារក្លែងដូចការចោទប្រកាន់ឡើយ ព្រោះឯកសារ (ពាក្យស្នើសុំប្រើប្រាស់ដីធ្លីលេខ ១២២០ ដប និងលេខ ១២៩០ ដប ដែលយកមកប្រើប្រាស់ក្នុងពាក្យបណ្តឹងជាឯកសាររបស់អាជ្ញាធរមូលដ្ឋាន ហើយការអះអាង និងតតាំងសិទ្ធិជាមួយតតិយជន ដែលមករំលោភបំពាន គឺជាយន្តការនៃការប្រើប្រាស់សិទ្ធិស្របច្បាប់ ដែលត្រូវបានបញ្ជាក់ដោយឯកសាររបស់អាជ្ញាធរមូលដ្ឋានប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ដើមបណ្តឹងពុំបានធ្វើការប្តឹង និងមិនមានឆន្ទៈក្នុងការប្តឹងកូនក្តីមកតុលាការមានសមត្ថកិច្ចឡើយ ដោយ

មានបុគ្គលដទៃទៀតបានប្រើប្រាស់ស្នាមមេដៃរបស់ឈ្មោះ [redacted] មេ ឈ្មោះ [redacted] ជ្រឹម ដែលជាអ្នកជាប់ព្រំដីរបស់កូនក្តីខ្ញុំ ដើម្បីយកទៅប្រើប្រាស់ទាញយកផលប្រយោជន៍លើករណីនេះ។ សព្វថ្ងៃនេះកូនក្តីខ្ញុំកំពុងស្វែងរក និងស្រាវជ្រាវរកបុគ្គលទុច្ចរិតទាំងនោះ ដើម្បីចាត់វិធានការតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាចំពោះសកម្មភាព និងទង្វើបំពានច្បាប់។ ម្យ៉ាងវិញទៀត តុលាការកំពូលបានសម្រេចផ្តល់សិទ្ធិឱ្យកូនក្តីយើងខ្ញុំជាម្ចាស់កម្មសិទ្ធិស្របច្បាប់តាមអំណាចសាលដីកា និងចូលជាស្ថាពររួចមកហើយ ដូចនេះបទល្មើសដែលរងការចោទប្រកាន់ខាងលើ គឺមិនមានឡើយ។

**៣.៤. សំណូមពរ**

ខ្ញុំបាទជាមេធាវីការពារក្តីឱ្យកូនក្តីឈ្មោះ [redacted] ទិត្យ សូមធ្វើការសំណូមពរដូចខាងក្រោម សុំឱ្យតុលាការទទួលយកបញ្ជាបន្ទាន់បង្គំដែលលុបលាងចរិតនៃបទល្មើស ដែលត្រូវបានតុលាការជាន់ខ្ពស់ផ្នែករដ្ឋប្បវេណីសម្រេចសេចក្តីរួចហើយតាមរយៈសាលដីការដ្ឋប្បវេណីលេខ ៤៩ “ង” ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់តុលាការកំពូល និងសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្ញុំឈ្មោះ [redacted] ទិត្យ រួចផុតពីបទចោទ។

**៤. លោក [redacted] ធ្វើសេចក្តីសន្និដ្ឋានថា៖**

ខ្ញុំបាទស្នើសុំរក្សាតាមការសន្និដ្ឋាន របស់សហភាតាដដែល ឆ្លងតាមការសាកសួរដេញដោលលើជនជាប់ចោទឈ្មោះ [redacted] ទិត្យ ទី១ ដើមបណ្តឹងរដ្ឋប្បវេណី បានដកពាក្យបណ្តឹង ទី២ គ្មានធ្វើកោសលវិច័យបញ្ជាក់ថាជាស្នាមមេដៃក្លែងលើលិខិតផ្ទេរសិទ្ធិលេខ G៧១៤៣២ និងពាក្យស្នើសុំកាន់កាប់ឆ្នាំ១៩៩៣ មានប្លង់ G៧១២៦២ ត្រូវបានក្លែងដោយអ្នកណាឡើយ ព្រោះឯកសារចេញពីអាជ្ញាធរ។ ការក្លែងនេះគឺមិនមែនឡើយ ចេតនានៃការប្រើប្រាស់គឺលោក [redacted] ទិត្យ ប្រើប្រាស់ក្នុងតុលាការដោយខ្លួនជាសន្តតិជនដែលមានបងប្អូនគាត់ដូចសហភាតាបានលើកឡើង។ ហើយដើមបណ្តឹងរដ្ឋប្បវេណី បានដកពាក្យបណ្តឹងដោយមេធាវីមិនដឹងទទួលសិទ្ធិតាមរយៈណានោះទេ គឺដើមបណ្តឹងរដ្ឋប្បវេណីផ្តិត ដោយសារតែការឆបោក ឈ្មោះ [redacted] ផុន [redacted] សំឡូត និងឈ្មោះ [redacted] ស៊ីម ដោយបុគ្គលទាំងនោះមានទំនាស់ផលប្រយោជន៍ ដែលនេះជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំបាទ ដែលដើមបណ្តឹងរដ្ឋប្បវេណីដាក់មកនេះមិនមានធាតុផ្សំគ្រប់គ្រាន់ ហេតុនេះស្នើសុំតុលាការសម្រេចឱ្យកូនក្តីខ្ញុំបាទរួចខ្លួន។

- ***ក្រោយពីបាន ស្តាប់កិច្ចពិភាក្សាដេញដោលរួចហើយ***
- ***ក្រោយពីបាន ស្តាប់សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល***

**សំអាងហេតុ**

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្តី**

សាលាដំបូងខេត្តកណ្តាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **៥៦២ រ.ក** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ទិត្យ** ភេទប្រុស កើតឆ្នាំ១៩៨៥ (អាយុ ៣៥ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **ប្រើប្រាស់ឯកសារក្លែង** ប្រព្រឹត្តនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២២ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា **៦២៨** នៃក្រមព្រហ្មទណ្ឌ តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ។

ខ. អំពីដែនកំណត់នៃការប្ដឹងចំពោះអង្គហេតុ និងបុគ្គល

ដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្ដាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្ដឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] ទិត្យ ៕

គ. អំពី ពិរុទ្ធភាព

១. បទចោទប្រកាន់ចំពោះជនជាប់ចោទគឺជាបទ **ប្រើប្រាស់ឯកសារក្លែង** តាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យនៃការប្រើប្រាស់ឯកសារក្លែងថា "**ការប្រើប្រាស់លិខិតក្លែងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល**"។

២. តាមភស្តុតាងក្នុងសំណុំរឿងបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ទិត្យ ពុំបានបំពេញធាតុសត្យានុម័តនៃបទ **ប្រើប្រាស់ឯកសារក្លែង** ប្រព្រឹត្តនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ព្រោះដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជ្រឹម ឈ្មោះ [redacted] មេ បានធ្វើការដកពាក្យបណ្ដឹងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៦២ អ.ក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្ដាល ដូចមានក្នុងលិខិតដកពាក្យបណ្ដឹងចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ជ្រឹម និងលិខិតដកពាក្យបណ្ដឹងចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] មេ ដោយដើមបណ្ដឹងរដ្ឋប្បវេណីមិនបានផ្ដិតស្នាមមេដៃ និងមិនមានឆន្ទៈក្នុងការប្ដឹងជនជាប់ចោទឈ្មោះ [redacted] ទិត្យ ដូចពាក្យបណ្ដឹងឡើយ ហើយមិនបានពឹងពាក់មេធាវីឱ្យធ្វើការប្ដឹងជនជាប់ចោទឡើយ។ ម្យ៉ាងទៀត បើពិនិត្យអំពីសាលដីការដ្ឋប្បវេណីលេខ ៤៩ "ង" ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់តុលាការកំពូល ត្រង់សេចក្ដីសម្រេចបញ្ចប់ ចំណុចទី៤ *"សម្រេចប្រគល់ដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ និងលេខ ៤៧-១៤៣២ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៣ ដោយផ្អែកលើគំនូសបង្ហាញទីតាំងដីទំនាស់ទាំងពីរកន្លែងដែលបានគូសកំណត់អំពីទំហំដី និងទីតាំង ភិនភាគដីនោះ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ ដែលបានគូសដោយមន្ត្រីជំនាញសុរិយោដីនៃមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល ឱ្យទៅសហដើមចោទឈ្មោះ [redacted] លេខា, ឈ្មោះ [redacted] លីណា, ឈ្មោះ [redacted] លីទី និងឈ្មោះ [redacted] ទិត្យ គ្រប់គ្រង កាន់កាប់អាស្រ័យផល ចាត់ចែងក្នុងនាមជាម្ចាស់សិទ្ធិលើដីទាំងពីរកន្លែងនេះតាមច្បាប់"*។ ចំណុចនេះ បង្ហាញថា ឯកសារដែលត្រូវបានកត់សម្គាល់ជាឯកសារក្លែង ត្រូវបានតុលាការកំពូលធ្វើការពិនិត្យភស្តុតាង និងទទួលស្គាល់ឯកសារខាងលើនេះ ហើយបានសម្រេចដូចមានខ្លឹមសារខាងលើនេះ។ លើសពីនេះ តុលាការរកមិនឃើញថា ក្នុងរឿងក្ដីនេះ មានភស្តុតាងណាមួយដែលអាចបញ្ជាក់ថា លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១២២០ បជ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩២ និងកំណត់ហេតុអង្កេតដីដែលមានស្នាមមេដៃរបស់ឈ្មោះ [redacted] មេ ទទួលស្គាល់ជាអ្នកជាប់ព្រំខាងត្បូង និងលិខិតកាន់កាប់ដីធ្លីលេខ ១២៩០ បជ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ និងកំណត់ហេតុអង្កេតដីដែលមានស្នាមមេដៃរបស់ឈ្មោះ អួង ជ្រឹម ទទួលស្គាល់



Scanned with CamScanner

ជាអ្នកជាប់ព្រំខាងកើត ដែលមានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ជាឯកសារក្លែងនោះទេ។ ដោយឡែកចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ គឺថា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ពុំមានភាពគ្រប់គ្រាន់លើវិធានភស្តុតាង និងការស្វែងរកធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ធៀបទៅនឹងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនោះទេ។ ប៉ុន្តែចំពោះសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដែលបានសន្និដ្ឋានថា ការដកពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ជ្រឹម តាមលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ និងការដកពាក្យបណ្តឹងរបស់ឈ្មោះ [redacted] មេ តាមលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ ជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាស្របតាមមាត្រា ៨ កថាខណ្ឌទី ២ ក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា “**ដោយការដកពាក្យប្តឹងនៅក្នុងករណីដែលពាក្យប្តឹងនេះ ជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ**” គឺជាការមិនត្រឹមត្រូវទេ ព្រោះតាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ លក្ខខណ្ឌនេះ ពុំមានចែងក្នុងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែជំនួសមកវិញ ដូចមានក្នុងសំអាងហេតុខាងលើ គឺពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការកំណត់អំពីពិរុទ្ធភាពនៃបទល្មើសនេះ។

៣. តាមសំអាងហេតុចំណុចទី១ ដល់ទី២ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បានបង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ទិត្យ** ពុំបានបំពេញធាតុអត្តនោម័តនៃបទ **ប្រើប្រាស់ឯកសារក្លែង** ប្រព្រឹត្តនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ។

**៤.** តាមសំអាងហេតុចំណុចទី១ និងទី៣ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើបានបង្ហាញថា **អំពើរបស់**ជនជាប់ចោទឈ្មោះ [redacted] **ទិត្យ** ពុំបានបំពេញធាតុផ្សំនៃបទ **ប្រើប្រាស់ឯកសារក្លែង** ប្រព្រឹត្តនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ។

**ឃ. អំពី ការប្រកាសអំពីពិរុទ្ធភាព**

តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) ខាងលើ បង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] **ទិត្យ** ពុំបានបំពេញធាតុផ្សំនៃបទ **ប្រើប្រាស់ឯកសារក្លែង** ប្រព្រឹត្តនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ទិត្យ** ពុំមានពិរុទ្ធភាពពីបទ **ប្រើប្រាស់ឯកសារក្លែង** ប្រព្រឹត្តនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៕

**ង. អំពី បណ្តឹងរដ្ឋប្បវេណី**

ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] **ទិត្យ** ត្រូវបានរកឃើញថា ពុំមានពិរុទ្ធភាពលើអង្គហេតុដែលបានប្តឹងមកតុលាការ ហេតុដូច្នេះ តុលាការនឹងសម្រេចពិចារណាអំពីសំណងនៃការខូចខាត និងសំណងជំងឺចិត្តប្រសិនបើមានការទាមទារ។



Scanned with CamScanner

## សេចក្តីសម្រេច

ក. ប្រកាសថា ពុំមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ទិត្យ ភេទប្រុស កើតឆ្នាំ១៩៨៥ (អាយុ ៣៥ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **ប្រើប្រាស់ឯកសារក្លែង** ប្រព្រឹត្តនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ។

**ខ.** ឱ្យជនជាប់ចោទឈ្មោះ [redacted] ទិត្យ ភេទប្រុស កើតឆ្នាំ១៩៨៥ (អាយុ ៣៥ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ រួចខ្លួនពីបទ **ប្រើប្រាស់ឯកសារក្លែង** ប្រព្រឹត្តនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

***សំណុំរឿងព្រហ្មទណ្ឌនេះ ជំនុំជម្រះជាសាធារណៈចាត់ទុកថាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងនៅចំពោះមុខជនជាប់ចោទ។***

***សាលក្រមព្រហ្មទណ្ឌនេះប្រកាសជាសាធារណៈនៅថ្ងៃ ពុធ ០៥ រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ៣ នៅសាលសវនាការលេខ០១។***

***ភាគីដែលមានបំណងធ្វើបណ្តឹងទាស់ ឬបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍នេះ តាមការកំណត់របស់ច្បាប់។***

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ០៥ រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner